ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

# ថវិកាសង្ខេប ឆ្នាំ ២០២០

## BUDGET IN BRIEF     Fiscal Year 2020

នាយកដ្ឋានថវិកានីយកម្ម

អគ្គនាយកដ្ឋានថវិកា

# មាតិកា


| | ទំព័រ |
|---|---|
| ជំពូក ១ បរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០២០ | ២ |
| ១.១. បញ្ហាប្រឈម និង ហានិភ័យ | ៣ |
| ១.២. គោលការណ៍នៃការរៀបចំថវិកាឆ្នាំ ២០២០ | ៣ |
| ជំពូក ២ ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២០ | ៤ |
| ២.១. សូចនាករសេដ្ឋកិច្ច | ៤ |
| ២.២. កំណើនតាមវិស័យសំខាន់ៗ | ៦ |
| ជំពូក ៣ ក្របខណ្ឌថវិកាឆ្នាំ ២០២០ | ៩ |
| ៣.១. ស្ថានភាពចំណូលថវិការដ្ឋ | ១០ |
| ៣.២. ស្ថានភាពចំណាយថវិការដ្ឋ | ១២ |
| ៣.៣. ថវិកាកម្មវិធីនៃក្រសួង ស្ថាប័ន | ១៩ |
| ៣.៤. ការកំណត់ពិតាននៃការខ្ចីសម្រាប់ឆ្នាំ ២០២០ | ៣៧ |
| ៣.៥. គម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ | ៣៨ |
| ៣.៦. ស្ថានភាពបំណុល | ៤០ |
| ជំពូក ៤ បទប្បញ្ញត្តិស្ដីពីពន្ធដារ | ៤១ |
| ជំពូក ៥ សេចក្ដីសន្និដ្ឋាន | ៤៣ |
| ជំពូក ៦ តារាងឧបសម្ព័ន្ធ | ៤៥ |
| ៦.១. ចំណាយថវិកាចរន្តរបស់ក្រសួង ស្ថាប័ន តាមកម្មវិធី អនុកម្មវិធី | ៤៥ |
| ៦.២. ចំណាយថវិកាសរុបរបស់ក្រសួង ស្ថាប័ន | ៧២ |

## ជំពូក ១ បរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០២០

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ ត្រូវបានរៀបចំឡើងនៅក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជាបាន និងកំពុងទទួលផលពីសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ និងស្ថិរភាពនយោបាយ ដែលកើតចេញពីនយោបាយ **ឈ្នះ-ឈ្នះ** ដោយបានប្រែក្លាយជោគវាសនារបស់ប្រជាជាតិមួយដែលធ្លាប់ហែលឆ្លងកាត់នូវហាយនភាព និងទុក្ខវេទនារាប់មិនអស់ ឱ្យទៅជាជាតិសាសន៍មួយដែលមានវិបុលភាព និងការអភិវឌ្ឍរីកចម្រើន ទន្ទឹមគ្នានឹងមានការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស។ ដំណើរឈានឡើងនេះ បាននាំមកនូវមោទនភាពជាតិមិនធ្លាប់មានពីមុនមក ព្រមជាមួយនឹងក្តីសង្ឃឹម និងទំនុកចិត្តដ៏មុតមាំសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ក៏ដូចជាសង្គមជាតិទាំងមូល ក្នុងការបន្តអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាឱ្យឈានដល់ដំណាក់កាលអភិវឌ្ឍន៍ថ្មីមួយទៀត ពោលគឺប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ក្នុងន័យនេះ កម្ពុជាចាំបាច់ត្រូវត្រៀមខ្លួន និងពង្រឹងសមត្ថភាពផ្ទៃក្នុងឱ្យបានល្អ ដើម្បីទប់ទល់បញ្ហាប្រឈម និងហានិភ័យ ទាំងខាងក្នុង និងខាងក្រៅ ព្រមទាំងត្រូវធ្វើការវះកាត់ដោះស្រាយបញ្ហាជារចនាសម្ព័ន្ធរ៉ាំរ៉ៃមួយចំនួន ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង និងធ្វើពិពិធកម្មសេដ្ឋកិច្ចឱ្យកាន់តែខ្លាំងក្លា និងដើម្បីអាចឈរដោយខ្លួនឯង ដោយមិនចាំបាច់ពឹងផ្អែកទៅលើប្រព័ន្ធអនុគ្រោះពន្ធពីប្រទេសផ្សេងៗ ទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។ ទន្ទឹមនេះ កម្ពុជាក៏ត្រូវខិតខំទ្វេដងក្នុងការទាក់ទាញការវិនិយោគ និងធុរកិច្ច ដែលអាចនឹងហូរចូលកម្ពុជាដោយសារសង្គ្រាមពាណិជ្ជកម្ម និងត្រូវក្តាប់យកនូវកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថល ព្រមទាំងត្រូវសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុផងដែរ។ លើសពីនេះទៅទៀត កម្ពុជាត្រូវកសាងនូវប្រព័ន្ធរដ្ឋបាល-សាធារណៈមួយ ដែលកាន់តែស្អាតស្អំ ឆ្លាតវៃ និងមានសមត្ថភាពខ្លាំងពូកែ ដើម្បីអាចគ្រប់គ្រង និងដោះស្រាយបញ្ហាសង្គម និងសេដ្ឋកិច្ច ដែលកាន់តែធំនិងស្មុគស្មាញជាងមុន ប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្នុងរយៈពេលវែង។

ឈរលើមូលដ្ឋានខាងលើនេះ ថវិកាឆ្នាំ២០២០ ត្រូវបានគិតគូរ និងរៀបចំឡើង ដើម្បីទ្រទ្រង់ដល់និរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ ចលនការនៃការកែទម្រង់ ពង្រឹងប្រព័ន្ធផ្ទៃក្នុង ដើម្បីពង្រឹងភាពជាម្ចាស់ទៅថ្ងៃអនាគត និងដើម្បីត្រៀមខ្លួនទប់ទល់ និងផ្តល់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះរាល់បញ្ហាប្រឈម និងហានិភ័យ ទាំងខាងក្នុង និងខាងក្រៅប្រទេស ពិសេសដើម្បីសម្រេចឱ្យបានជាអតិបរមានូវគោលដៅជាយុទ្ធសាស្ត្រទាំង៤ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ ដើម្បី កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព ÷ កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០ ដែលជា របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច នៃ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា។

**របៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦**

- ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ក្នុងរង្វង់ ៧% ប្រកបដោយចីរភាព និងធន់នឹងវិបត្តិ
- បង្កើតការងារឱ្យបានកាន់តែច្រើន ទាំងបរិមាណ និងគុណភាព ជូនដល់ប្រជាជន
- សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ឱ្យស្ថិតនៅក្នុងអត្រាទាបជាង ១០%
- បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

## ១.១. បញ្ហាប្រឈម និង ហានិភ័យ

សម្រាប់ឆ្នាំ ២០២០ កម្ពុជាអាចបន្តសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៦,៥% ក្នុង ក្នុងបរិបទនៃការកើនឡើងនូវបញ្ហាប្រឈម និងហានិភ័យទាំងក្នុង និងក្រៅប្រទេស ដែលបាន និងកំពុងបង្កការគំរាមមកលើចីរភាព និងនិរន្តរភាពនៃការអភិវឌ្ឍកម្ពុជា ដូចជា÷

**កត្តាខាងក្នុង**

- ថ្លៃអគ្គិសនីសម្រាប់វិស័យផលិតកម្ម និងអាជីវកម្មនៅមានកម្រិតខ្ពស់នៅឡើយ ធៀបនឹងប្រទេសជិតខាង
- បញ្ហាស្ថេរភាពនៃការផ្គត់ផ្គង់អគ្គិសនី
- ភាពទន់ខ្សោយនៃប្រព័ន្ធដឹកជញ្ជូន និងឡជីស្ទីក
- ការបន្តកើនឡើងនៃប្រាក់ឈ្នួលអប្បបរមា និង បញ្ហាកង្វះកម្លាំងពលកម្មជំនាញ
- នីតិវិធីស្មុគស្មាញ និងការបន្តនៅមានសេសសល់នូវកម្រៃសេវាក្រៅផ្លូវការ ដែលបង្កជាបញ្ហាដល់ការធ្វើធុរកិច្ច

**កត្តាខាងក្រៅ**

- សង្គ្រាមពាណិជ្ជកម្មពិភពលោក
- បញ្ហានយោបាយ និងសន្តិសុខជាសកល
- បញ្ហាចលាចលនៅទីក្រុងហុងកុង
- ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ
- ភាពមិនប្រាកដប្រជានៃប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាមួយដៃគូមួយចំនួន

### ១.២. គោលការណ៍នៃការរៀបចំថវិកាឆ្នាំ ២០២០

ថវិកាឆ្នាំ ២០២០ ត្រូវបានរៀបចំឡើងដោយផ្អែកលើ **អភិក្រម** និង **គោលការណ៍** សំខាន់ចំនួន ៩ រួមមាន÷

១. គោរពឱ្យបាននូវក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច

២. ធានាចីរភាព និងសមិទ្ធកម្មនៃចំណូល

៣. ផ្សារភ្ជាប់ការប្រមូលចំណូល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងលទ្ធផលការងារជាមួយនឹងការវិភាជថវិកា

៤. ការកំណត់លំដាប់អាទិភាព

៥. ការយកចិត្តទុកដាក់លើមនុស្ស

៦. កំណត់តម្លៃជាក់ស្តែងនៃកម្មវិធី / សកម្មភាព

៧. ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត

៨. ការរក្សាតុល្យភាព និងចីរភាពថវិកា

៩. បន្តពង្រឹងភាពប្រុងប្រយ័ត្នខ្ពស់ក្នុងការគ្រប់គ្រងបំណុលសាធារណៈ

## ជំពូក ២ <u>ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២០</u>

### ២.១. សូចនាករសេដ្ឋកិច្ច

តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចកម្ពុជានឹងសម្រេចបានក្នុងអត្រា ៦,៥% ដែលកំណើននេះ មានការថមថយបើធៀបទៅនឹងកំណើនឆ្នាំ ២០១៩ ដែលត្រូវបានប៉ាន់ស្មានថាអាចសម្រេចបាន ៧,១% ដែលធ្វើឱ្យ ផសស ថ្លៃបច្ចុប្បន្នឆ្នាំ ២០២០ ស្ថិតនៅក្នុងរង្វង់ ១១៩ ០៣៤ ២២៩ លានរៀល សមមូលនឹងប្រមាណ ២៩ ៣៦២ លានដុល្លារអាមេរិក ហើយ ផសស សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ ១ ៨១៦ ដុល្លារអាមេរិក ធៀបនឹង ១ ៦៧៩ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៩។ ចំណែកឯ**អត្រាប្តូរប្រាក់រៀល** គឺនៅតែបន្តស្ថិតនៅក្នុងរង្វង់ ៤ ០៥៤ រៀល ក្នុងមួយដុល្លារអាមេរិក ក្នុងឆ្នាំ ២០២០។ **ឱនភាពគណនីចរន្ត** (រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងស្ថិតក្នុងអត្រា ៩,៣% នៃ ផសស ក្នុងឆ្នាំ២០២០។ ភាពល្អប្រសើរឡើងនៃគណនីចរន្តនេះនឹងឆ្លុះបញ្ចាំងតាមរយៈការរំពឹងទុកអំពីកំណើននៃវិហ្វូរប្រាក់បង្វែរឯកជនពីបរទេស និង

ភាពរួមតូចនៃឱនភាពសមតុល្យពាណិជ្ជកម្ម ដោយសារការថមថយនៃការនាំចូលវត្ថុធាតុដើមកាត់ដេរ ស្របទៅនឹងកំណើនទាបនៃការនាំចេញផលិតផលកាត់ដេរ។ **ទុនបម្រុងអន្តរជាតិសរុប** ត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ប្រមាណ ១៣ ០០៧ លានដុល្លារអាមេរិក ដែលធានាការនាំចូលបាន ៦,១ ខែ នៅឆ្នាំ ២០២០។

| សូចនាករសេដ្ឋកិច្ច | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| | អនុវត្ត | ប៉ាន់ស្មាន | ព្យាករណ៍ |
| ផសស តាមថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | ៩៨ ៧៨៦ | ១០៨ ៥៩០ | ១១៩ ០៣៤ |
| កំណើនពិតនៃ ផសស (%) | ៧,៥% | ៧,១% | ៦,៥% |
| ផសស សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក) | ១ ៥៤៨ | ១ ៦៧៩ | ១ ៨១៦ |
| អតិផរណា (ជាមធ្យមប្រចាំឆ្នាំ) | ២,៥% | ២,៨% | ២,៩% |
| អត្រាប្តូរប្រាក់ (ដុល្លារអាមេរិក/រៀល) | ៤ ០៥៣ | ៤ ០៥៤ | ៤ ០៥៤ |
| សមតុល្យគណនីចរន្ត (% នៃ ផសស) | -១០,៧% | -៩,៦% | -៩,៣% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | ១០ ០៥២ | ១១ ៥០៥ | ១៣ ០០៧ |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | ៥,៦ | ៥,៨ | ៦,១ |




- អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ ត្រូវបានប៉ាន់ស្មានថាស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្នុងអត្រា ២,៩% ក្នុងឆ្នាំ ២០២០ ស្របនឹងការរំពឹងទុកនៃការកើនឡើងខ្លះនូវថ្លៃម្ហូបអាហារជាពិសេសថ្លៃអង្ករ ខណៈដែលថ្លៃប្រេងលើទីផ្សារអន្តរជាតិត្រូវបានរំពឹងថានឹងបន្តធ្លាក់ចុះ ដែលអាចបណ្តាលមកពីឥទ្ធិពលនៃសង្គ្រាមពាណិជ្ជកម្ម។
- អត្រាប្តូរប្រាក់រៀល គឺនៅតែបន្តស្ថិតនៅក្នុងរង្វង់ ៤ ០៥៤ រៀល ក្នុងមួយ ដុល្លារអាមេរិកក្នុងឆ្នាំ ២០២០ ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ជំនឿទុកចិត្តពីសំណាក់សាធារណជនលើការប្រើប្រាស់ប្រាក់រៀល តាមរយៈការអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការបន្តពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុ។

## ២.២. កំណើនតាមវិស័យសំខាន់ៗ

តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ ២០២០ ត្រូវបានទ្រទ្រង់ដោយ÷

**(ទី១)**-កំណើននៃវិស័យឧស្សាហកម្មត្រូវបានព្យាករថានឹងមានការថមថយមកក្នុងរង្វង់ អត្រា ៨,៩% ក្នុងឆ្នាំ ២០២០ ធៀបនឹង ១០,៧% ក្នុងឆ្នាំ ២០១៩ ដោយសារការរំពឹងទុកនូវកំណើនយឺតនៃអនុវិស័យកាត់ដេរ និងកំណើនយឺតបន្តិចនៃអនុវិស័យសំណង់ ទោះបីជាអនុវិស័យឧស្សាហកម្មមិនមែនកាត់ដេរទាំងសម្រាប់បម្រើឱ្យការនាំចេញ និងទីផ្សារក្នុងស្រុកអាចសម្រេចបានកំណើនល្អប្រសើរជាងឆ្នាំ ២០១៩ បន្តិចក្តី។ អនុវិស័យកាត់ដេរត្រូវបានព្យាករថានឹងមានកំណើនទាប ដោយសារការថមថយកំណើននៃសេដ្ឋកិច្ចពិភពលោក និងការរំពឹងទុកនូវផលប៉ះពាល់ដែលអាចបណ្តាលមកពីភាពមិនច្បាស់លាស់នៃប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាមួយដៃគូមួយចំនួន។ ជាមួយគ្នានេះដែរ បើយោងតាមនិន្នាការក្នុងពេលថ្មីៗនេះ អនុវិស័យសំណង់អាចប្រឈមនឹងការកែតម្រូវផ្នែកទីផ្សារ ដែលនឹងអាចធ្វើឱ្យកំណើននៃវិស័យនេះមានការថមថយខ្លះ។ អនុវិស័យឧស្សាហកម្មមិនមែនកាត់ដេរ ដូចជា ម្ហូបអាហារនិងភេសជ្ជៈ ឧស្សាហកម្មដំឡើងយានយន្ត គ្រឿងបង្គុំអេឡិកត្រូនិក គ្រឿងបន្លាស់ គ្រឿងសង្ហារិម និងស៊ីម៉ង់ត៍ជាដើម ទាំងសម្រាប់បម្រើឱ្យការនាំចេញ និងតម្រូវការទីផ្សារក្នុងស្រុក នឹងមានសន្ទុះកំណើនខ្ពស់ទាំងក្នុងទិដ្ឋភាពនៃការពង្រីកការវិនិយោគដែលមានស្រាប់ និងទាំងក្នុងទិដ្ឋភាពនៃការវិនិយោគថ្មី។

**(ទី២)**-វិស័យសេវាកម្មត្រូវបានព្យាករថានឹងមានកំណើនយឺតក្នុងរង្វង់ ៦,៤% ធៀបនឹង ៦,៧% ក្នុងឆ្នាំ ២០១៩ ដោយសារការរំពឹងទុកនូវកំណើនយឺតនៃអនុវិស័យអចលនទ្រព្យ ខណៈអនុវិស័យលក់ដុំ-រាយ និង អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន នៅមានកំណើនល្អប្រសើរ។ អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋានអាចសម្រេចបានកំណើនប្រហាក់ប្រហែលនឹងឆ្នាំ ២០១៩ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើននៃចំនួនភ្ញៀវទេសចរអន្តរជាតិ ពិសេស មកពីតំបន់អាស៊ី ដោយសារការលើកទឹកចិត្តឱ្យមានការបើកជើងហោះហើរត្រង់កាន់តែច្រើន និងការដាក់ចេញនូវគោលនយោបាយនានាក្នុងការទាក់ទាញភ្ញៀវទេសចរបន្ថែម។ អនុវិស័យលក់ដុំ-រាយនៅរក្សាកំណើនល្អប្រសើរ ដែលគាំទ្រដោយកំណើននៃការប្រើប្រាស់ក្នុងស្រុក ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ។ ដោយឡែក អនុវិស័យអចលនទ្រព្យត្រូវបានព្យាករថានឹងមានកំណើនយឺតដោយសារការរំពឹងទុកនៃការថមថយលើតម្រូវការសំណង់អគារដែលមានថ្លៃខ្ពស់។

**(ទី៣)**-វិស័យកសិកម្មអាចសម្រេចបានកំណើនប្រហាក់ប្រហែលទៅនឹងឆ្នាំ ២០១៩ ក្នុងរង្វង់ ១,៧%។ ប៉ុន្តែផ្អែកតាមការវិវត្តក្នុងរយៈពេលថ្មីៗកន្លងមកនេះ កំណើននេះអាចថមថយខ្លះ ដោយសារការបន្តកំណើនយឺតនៃអនុវិស័យដំណាំ បើទោះបីអនុវិស័យនេសាទ និងចិញ្ចឹមសត្វមានកំណើនខ្ពស់ជាងឆ្នាំមុនបន្តិចក្តី។ អនុវិស័យដំណាំ ត្រូវបានរំពឹងថានឹងអាចបន្តកំណើនទាបប្រហាក់ប្រហែលនឹងឆ្នាំមុន ដោយសារកំណើនផលិតភាពទាប ភាពមិនអំណោយផលនៃកត្តាអាកាសធាតុ និងភាពមានកម្រិតនៃការវិនិយោគលើវិស័យកែច្នៃកសិផល ថ្លៃដើមផលិតកម្មខ្ពស់ធៀបនឹងប្រទេសជិតខាង ភាពទន់ខ្សោយនៃហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងសមត្ថភាពស្ថាប័ន។ ដោយឡែក អនុវិស័យនេសាទត្រូវបានរំពឹងថានឹងមានកំណើនលើសពីឆ្នាំ ២០១៩ បន្តិច ដែលត្រូវបានជំរុញដោយការបន្តកំណើននៃអនុវិស័យវារីវប្បកម្ម ស្របតាមនិន្នាការកើនឡើងនៃការវិនិយោគពីសំណាក់វិស័យឯកជន និងការចូលរួមពីដៃគូអភិវឌ្ឍន៍។ អនុវិស័យចិញ្ចឹមសត្វត្រូវបានព្យាករថានឹងមានកំណើនលើសពីឆ្នាំមុនបន្តិច ដោយសារតែការពង្រីកផលិតកម្មជ្រូក និងមាន់តាមបែបពាណិជ្ជកម្មក្នុងទម្រង់ជាកិច្ចសន្យារវាងកសិករខ្នាតមធ្យម និងក្រុមហ៊ុនឯកជន។



**ជំពូក ៣ <u>ក្របខណ្ឌថវិកាឆ្នាំ ២០២០</u>**

ឈរលើគោលការណ៍ខាងលើ ក៏ដូចជាក្នុងក្របខណ្ឌនៃកំណើនសេដ្ឋកិច្ចដែលត្រូវបានគ្រោងក្នុងរង្វង់ ៦,៥% ព្រមជាមួយនឹងសេណារីយ៉ូចំណូលដែលមានលក្ខណៈសុទិដ្ឋិនិយម និងដោយឈរលើមូលដ្ឋាននៃលទ្ធផលល្អប្រសើរនៃការអនុវត្តចំណូល ជាពិសេស ចំណូលគយ និងចំណូលពន្ធដារឆ្នាំ ២០១៨ និងឆ្នាំ ២០១៩, ក្របខណ្ឌថវិកាឆ្នាំ ២០២០ ត្រូវបានរៀបចំក្រោមការកំណត់ដូចតទៅ៖

| សូចនាករថវិកា | ២០១៨ | | ២០១៩ | ២០២០ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | ច្បាប់ |
| **ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ថវិកាជាតិ (%ផសស)** | ១៨,៨២ | ២២,២៨ | ១៩,៥១ | ២២,១៣ |
| *ចំណូលចរន្ត (%ផសស)* | ១៨,៦៣ | ២២,០៨ | ១៩,៣៣ | ២១,៩៦ |
| **ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ (%ផសស)** | ២៤,៦៧ | ២៤,៥៨ | ២៥,០២ | ២៨,០១ |
| *ចំណាយចរន្ត (%ផសស)* | ១៦,១៤ | ១៦,៤៨ | ១៦,៤៩ | ១៦,៦៥ |
| **អតិរេកចរន្ត (%ផសស)** | ២,៤៩ | ៥,៦១ | ២,៨៤ | ៥,៣១ |
| **ឱនភាពសរុប (%ផសស)** | -៥,៨៦ | -២,៣០ | -៥,៥១ | -៥,៨៨ |

- **<u>ចំណូលក្នុងប្រទេសថវិការដ្ឋ</u>** ត្រូវបានគ្រោង ២២,១៣% នៃ ផសស ស្មើនឹងចំនួន ២៦ ៣៣៦ ៤៤៣ លានរៀល។
- **<u>ចំណាយសរុបថវិការដ្ឋ</u>** ត្រូវបានគ្រោង ២៨,០១% នៃ ផសស ស្មើនឹងចំនួន ៣៣ ៣៣៩ ៦៣៣ លានរៀល។
- **<u>អតិរេកថវិកាចរន្ត</u>** អាចរក្សាបានក្នុងកម្រិតប្រមាណ ៥,៣១% នៃ ផសស។
- **<u>ឱនភាពថវិកាសរុប</u>** ស្មើនឹង -៥,៨៨% នៃ ផសស ស្របតាមគោលនយោបាយវិត្ថារកម្មថវិកា (Stimulus Budget)។




## ៣.១. ស្ថានភាពចំណូលថវិការដ្ឋ

ក្នុងក្របខណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលត្រូវបង្កើនចំណូលសរុបថវិការដ្ឋ ឬ ចំណូលសរុបថវិកាជាតិ ឱ្យស្មើនឹង ៣២ ៦៣៩ ៦៣៣ លានរៀល ក្នុងនោះ ចំណូលចរន្តថ្នាក់ជាតិ ឱ្យស្មើនឹង ២៣ ៨៩៩ ៣២៤ លានរៀល (ដែលរួមមាន ចំណូលសារពើពន្ធ ២១ ០៩១ ១៤៥ លានរៀល និង ចំណូលមិនមែនសារពើពន្ធ ២ ៨០៨ ១៧៩ លានរៀល)។ ដោយឡែក សម្រាប់ចំណូលមូលធនថវិការដ្ឋ ត្រូវបានគ្រោងចំនួន ៦ ៤៩៦ ៥៣១ លានរៀល, ត្រូវជា ៥,៤៦% នៃ ផសស គឺមានកំណើន ១២,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ ក្នុងនោះចំណូលមូលធនដោយហិរញ្ញប្បទានពីក្រៅប្រទេស ស្មើនឹងប្រមាណជិត ១៩% នៃចំណាយថវិការដ្ឋសរុបឆ្នាំ ២០២០ ប៉ុណ្ណោះ។


ចំណូលមូលធនក្នុងប្រទេស
193,341
ចំណូលមូលធនក្រៅប្រទេស
6,303,190
ចំណូលចរន្តថវិកាថ្នាក់ក្រោមជាតិ
2,243,778
ចំណូលសរុប
ថវិការដ្ឋ
៣២ ៦៣៩ ៦៣៣
ចំណូលចរន្តថវិកាថ្នាក់ជាតិ
23,899,324
ចំណូលមិនមែនសារពើពន្ធ
12%
ចំណូលពន្ធដារ
39%
ចំណូលចរន្តថ្នាក់ជាតិ
២៣ ៨៩៩ ៣២៤
លានរៀល
ចំណូលគយ និងរដ្ឋាករ
49%


ពន្ធផ្ទាល់
24%
ពន្ធប្រយោល
76%
ពន្ធក្នុងប្រទេស
87%
ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស
13%

**<u>ចំណូលមូលធន</u>** ត្រូវសម្រេចឱ្យបានចំនួន ៦ ៤៩៦ ៥៣១ លានរៀល ក្នុងនោះ

- ចំណូលមូលធនក្នុងប្រទេស ១៩៣ ៣៤១ លានរៀល
- ចំណូលមូលធនក្រៅប្រទេស ៦ ៣០៣ ១៩០ លានរៀល

៣% • ត្រូវសម្រេចឱ្យបានចំនួន <u>១៩៣ ៣៤១</u> លានរៀល




៩៧% • មូលនិធិទ្រទ្រង់ថវិកា <u>២៥០ ០០០</u> លានរៀល

• មូលធនដោយហិរញ្ញប្បទានក្រៅប្រទេស <u>៦ ០៥៣ ១៩០</u> លានរៀល

### ៣.២. ស្ថានភាពចំណាយថវិការដ្ឋ

សម្រាប់ឆ្នាំ ២០២០ **ចំណាយសរុបថវិការដ្ឋ** ឬ **ចំណាយសរុបថវិកាជាតិ** ត្រូវបានគ្រោងចំនួន ៣៣ ៣៣៩ ៦៣៣ លានរៀល ត្រូវជា ២៨,០១% នៃ ផសស គឺមានកំណើន ២២,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ ដែលក្នុងនោះ (១)-**ចំណាយចរន្តថវិការដ្ឋ**មានចំនួន ១៩ ៨១៨ ៣០៦ លានរៀល ត្រូវជា ១៦,៦៥% នៃ ផសស គឺមានកំណើន ១០,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ និង (២)-**ចំណាយមូលធនថវិការដ្ឋ**មានចំនួន ១៣ ៥២១ ៣២៧ លានរៀល ត្រូវជា ១១,៣៦% នៃ ផសស គឺមានកំណើន ៤៦,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៩។




## ចំណាយចរន្ត

**បន្ទុកបុគ្គលិកសរុប ÷ ៩ ១៣៨ ៨៨០ លានរៀល**

- ថ្នាក់ជាតិ ÷ ៨ ៥៣៩ ៧៥២ លានរៀល
- ថ្នាក់ក្រោមជាតិ ÷ ៥៩៩ ១២៨ លានរៀល

**ក្រៅបន្ទុកបុគ្គលិកសរុប ÷ ១០ ៦៧៩ ៤២៦ លានរៀល**

- ថ្នាក់ជាតិ ÷ ៩ ៤៩៧ ១៣២ លានរៀល
- ថ្នាក់ក្រោមជាតិ ÷ ២ ២៦៧ ៧៥២ លានរៀល*

*****សំគាល់÷** ទំហំចំណាយចរន្តក្រៅបន្ទុកបុគ្គលិកថ្នាក់ក្រោមជាតិបានបូកបញ្ចូលនូវឥណទានឧបត្ថម្ភធនពីថ្នាក់ជាតិចំនួន ១ ០៨៥ ៤៥៨ លានរៀល។*

## ចំណាយមូលធន

**វិនិយោគសាធារណៈហិរញ្ញប្បទានក្នុងប្រទេស**

**សរុប÷** ៦ ៣៦២ ២១៥ លានរៀល

- ថ្នាក់ជាតិ ÷ ៥ ៨៩៩ ៨៥៩ លានរៀល
- ថ្នាក់ក្រោមជាតិ ÷ ៤៦២ ៣៥៦ លានរៀល

**វិនិយោគសាធារណៈហិរញ្ញប្បទានក្រៅប្រទេស**

៦ ០៥៣ ១៩០ លានរៀល

**ការទូទាត់ប្រាក់ខ្ចី** ១ ១០៥ ៩២២ លានរៀល

## ក. ចំណាយចរន្តថ្នាក់ជាតិ




### ក.១. ចំណាយលើបន្ទុកបុគ្គលិក

ចំណាយលើបន្ទុកបុគ្គលិក ត្រូវបានគ្រោងចំនួន ៨ ៥៣៩ ៧៥២ លានរៀល សម្រាប់ (១)-ការដំឡើងបៀវត្សមូលដ្ឋានក្នុងអត្រា ៧,០% តាមតម្លៃឯកតាសន្ទស្សន៍ ២ ៥០០ រៀល ដោយអនុវត្តន៍ចាប់ពីខែមករា ឆ្នាំ ២០២០, (២)-ការដំឡើងប្រាក់បំណាច់មុខងារនឹងត្រូវអនុវត្ត ចាប់ពីខែមេសា ឆ្នាំ ២០២០ ដោយផ្ដល់បន្ថែម ៣០ ០០០ រៀល ជូនមន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតក្រោម ៩៦០ ០០០ រៀល និង ចាប់ពីកម្រិត ៩៦០ ១០០ រៀល ដល់ ១ ១១០ ០០០ រៀល នឹងផ្ដល់បន្ថែមចំនួន ២០ ០០០ រៀល, (៣)-ការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យា ពី ៦៥០ ០០០ រៀល ទៅដល់ ៦៧០ ០០០ រៀល ដោយអនុវត្តន៍ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ ២០២០។ ចំពោះការបើក ប្រាក់បៀវត្សនឹងត្រូវធ្វើឡើងចំនួន ២ ដង ក្នុងមួយខែ តាមប្រព័ន្ធធនាគារចាប់ពីខែ មករា ឆ្នាំ ២០២០ ផងដែរ។

ក្រៅពីបានដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ រាជរដ្ឋាភិបាល ក៏បានគ្រោងថវិកាចំនួន **៤០ ប៊ីលានរៀល** ដោយឡែកផ្សេងទៀត សម្រាប់ផ្ដល់លទ្ធភាពដល់ក្រសួង-ស្ថាប័នអាចជ្រើសរើសមន្ត្រីមានសមត្ថភាព និងជំនាញខ្ពស់ចូលបម្រើការងាររដ្ឋ ដែលគ្របខណ្ឌ

និងគោលការណ៍នឹងត្រូវបានរៀបចំដាក់ឱ្យអនុវត្តន៍នៅក្នុងឆ្នាំ ២០២០។ លើសពីនេះ ថវិកាចំនួន **៥០ ប៊ីលានរៀល** ត្រូវបានគ្រោងសម្រាប់មូលនិធិថែទាំសុខភាពជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងនិវត្តជន និងបានបន្តគ្រោងថវិកាចំនួន **៦ ប៊ីលានរៀល** ដើម្បីទ្រទ្រង់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ នៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល។ ចំពោះប្រាក់សោធននិវត្តន៍ ក៏ត្រូវបានគ្រោងថវិកាចំនួន **៦០ ប៊ីលានរៀល** សម្រាប់ការដំឡើងរបបសោធនប្រចាំខែទាបបំផុតជូនដល់និវត្តជនដែលជាអតីតមន្ត្រីរាជការស៊ីវិល និងកង-កម្លាំងប្រដាប់អាវុធផងដែរ ក្នុងគោលដៅជួយគាំទ្រដល់ជីវភាពរបស់ពួកគាត់ ក៏ដូចជាការកាត់បន្ថយគម្លាតរបបសោធនរបស់និវត្តជន រវាងអ្នកទទួលបានសោធនទាប និងអ្នកទទួលបានសោធនខ្ពស់ និងរវាងនិវត្តជនថ្មី និងនិវត្តជនចាស់។

### ក.២. ចំណាយមិនមែនបន្ទុកបុគ្គលិក

ត្រូវបានគ្រោងចំនួន ៩ ៤៩៧ ១៣២ លានរៀល, មានសមាមាត្រ ស្មើនឹង ៥២,៦៥% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៧,៩៨% នៃ ផសស គឺមានកំណើន ៥,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៩, ហើយត្រូវបានវិភាជដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់តាមវិស័យនីមួយៗ ដូចខាងក្រោម÷

**<u>វិស័យរដ្ឋបាលទូទៅ</u>**

- លើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងចំណូល និងប្រមូលចំណូលសារពើពន្ធ
- គាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- គាំទ្រកំណែទម្រង់វិស័យដីធ្លី
- គាំទ្រ និងពង្រឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ ២០១៥-២០២៥
- គាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ
- បង្កើនប្រសិទ្ធភាពនៃកិច្ចការទូត តាមរយៈបង្កើនការគាំទ្រផ្នែកហិរញ្ញវត្ថុដល់មន្ត្រីការទូត
- គាំទ្រដល់ការរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចការប្រជុំកំពូល អាស៊ី-អឺរ៉ុប ឆ្នាំ ២០២០។

**<u>វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់</u>**

- គាំទ្រដល់ការពង្រឹងសមត្ថភាពរបស់នគរបាល និងកងកម្លាំងប្រដាប់អាវុធ
- បន្តផ្តោតការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ
- បង្កើនការគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ
- គាំទ្រកិច្ចដំណើរការរដ្ឋបាល និងអន្តរាគមន៍ផ្សេងៗ

- គាំទ្រដល់ដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- គាំទ្រការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព
- គាំទ្រដល់ការរៀបចំប្រព័ន្ធត្រួតពិនិត្យសន្តិសុខតាមច្រកព្រំដែន និងការផលិតលិខិតឆ្លងដែន
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ស្ត្រី និងកុមារ
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បន្តគាំទ្រសេវាឥតគិតថ្លៃរបស់គណៈមេធាវីកម្ពុជា។

**<u>វិស័យសង្គមកិច្ច</u>**

- ពង្រឹងគុណភាព និងគាំទ្រសេវាអប់រំ
- លើកកម្ពស់វិស័យកីឡាជាតិ
- អភិវឌ្ឍន៍ជំនាញ និងវិស័យការងារ
- លើកកម្ពស់គុណភាព និងការទទួលបានសេវាសុខាភិបាល
- ទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ
- ឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន
- បង្កើនការឧបត្ថម្ភដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាតាមបណ្តារាជធានី-ខេត្ត និងការឧបត្ថម្ភគាំទ្រមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម កាយសម្បទា ដើម្បីផ្តល់សេវាជូនជនពិការ
- ផ្តល់ថវិកាគាំទ្រដល់ការដោះស្រាយជីវភាពចំពោះជនក្រីក្រ និងចាស់ជរានៅតាមសហគមន៍
- ការពារ និងអភិរក្សធនធានធម្មជាតិ
- អភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ជាតិ
- សុខដុមនីយកម្មសាសនា។

**<u>វិស័យសេដ្ឋកិច្ច</u>**

- បន្តការលើកកម្ពស់បច្ចេកទេសកសិកម្ម
- ជំរុញផលិតកម្មស្បៀង ពិសេសការចិញ្ចឹមសត្វ និងមច្ឆាវប្បកម្ម
- ពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច និងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងជលផល
- បង្កើនការគាំទ្រដល់ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ
- ជំរុញការអភិវឌ្ឍទឹកស្អាត និងអនាម័យជនបទ

- ជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ
- ជំរុញការអភិវឌ្ឍផលិតផល និងការពង្រឹងគុណភាពសេវាទេសចរណ៍
- បន្តបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា
- បន្តជួសជុល ថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទ ព្រមទាំងការស្តារស្រះ ជីកស្រះ និងអណ្តូងទឹក ដើម្បីទប់ទល់នឹងគ្រោះរាំងស្ងួត
- ត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ
- អភិវឌ្ឍន៍ប្រព័ន្ធរដ្ឋបាលអេឡិកត្រូនិក
- ពង្រឹងនូវក្របខណ្ឌ និងយន្តការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម
- អភិវឌ្ឍន៍ប្រព័ន្ធស្តង់ដា និងមាត្រាសាស្ត្រ។

**ព័ត៌មានបន្ថែមសម្រាប់ទំហំចំណាយថវិកាសរុប (ចំណាយចរន្ត និងចំណាយមូលធន ក្នុងប្រទេស និងក្រៅប្រទេស) របស់ក្រសួង ស្ថាប័ន មានក្នុងតារាងឧបសម្ព័ន្ធទី ៣៩**

លើសពីនេះ សម្រាប់ឆ្នាំ ២០២០ រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាឆ្លើយតបនឹងសកម្មភាពគាំពារសង្គមដែលរួមមានជាអាទិ៍ ដូចជា÷

- **បន្តគាំទ្រការថែទាំសុខភាពសម្រាប់កម្មករ÷** បានត្រៀមថវិកាក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់ពង្រីកវិសាលភាពមូលនិធិសមធម៌ ដើម្បីផ្តល់លទ្ធភាពឱ្យកម្មករ (ទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ) ដែលមិនទាន់ជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ទទួលបានរបបថែទាំសុខភាពដូចប្រជាជនដែលមានប័ណ្ណក្រីក្រដែរ។
- **បន្តការឧបត្ថម្ភមាតុភាពសម្រាប់កម្មករនិយោជិត÷** បានគ្រោងនៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់បន្តបើកផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មការិនីនៅក្រោយពេលសម្រាលកូន និងសម្រាកលំហែមាតុភាព។
- **ការបន្តនិរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា÷** បន្តផ្តល់ថវិកាសម្រាប់បង្កើន "**មូលនិធិគន្ធបុប្ផាកម្ពុជា**" បន្ថែមលើថវិកាដែលត្រូវផ្តល់ផ្ទាល់ទៅមន្ទីរពេទ្យគន្ធបុប្ផាសម្រាប់ចំណាយប្រតិបត្តិការឆ្នាំ ២០២០, ដើម្បីធានានិរន្តភាព គុណភាព និងប្រសិទ្ធភាពរបស់មន្ទីរពេទ្យផង និងធានាការផ្តល់សេវាដោយមិនយកថ្លៃជូនដល់កុមារនៃគ្រួសារក្រីក្រផង។

- **ការបន្តសកម្មភាពរបស់រាជរដ្ឋាភិបាលក្នុងការចុះសួរសុខទុក្ខកម្មករ-កម្មការិនី** តាមបណ្តារោងចក្រ សហគ្រាស ដើម្បីស្វែងយល់និងរកដំណោះស្រាយសមស្របជូនកម្មករ-កម្មការិនី ក៏ដូចជាជំរុញគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។
- **កម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារតូច÷** បានគ្រោងថវិកាសម្រាប់ឧបត្ថម្ភពេលពិនិត្យផ្ទៃពោះ ចំនួន ៤ លើក, ១ លើក ៤ ម៉ឺនរៀល, ពេលសម្រាលកូននៅមណ្ឌលសុខភាព ឬ ពេទ្យរដ្ឋ ជូន ២០ម៉ឺនរៀល, ឧបត្ថម្ភ ១០ លើកទៀត ១លើក ៤ ម៉ឺនរៀល ពេលទៅទទួលថ្នាំបង្ការ រហូតដល់កុមារអាយុ ២ ឆ្នាំ។

## ខ. ចំណាយមូលធនថ្នាក់ជាតិ

ត្រូវបានគ្រោងចំនួន ១៣ ០៥៨ ៩៧១ លានរៀល មានសមាមាត្រ ស្មើនឹង ៤២,០% នៃចំណាយថវិកាថ្នាក់ជាតិសរុប ត្រូវជា ១០,៩៧% នៃ ផសស គឺមានកំណើន ៤៦,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៩។ គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិមានកំណើន ១៧០,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៩, ហើយត្រូវជា ៤,២២% នៃ ផសស គឺដោយសារការគ្រោងប្រើប្រាស់ក្នុងបរិបទនៃភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាមួយដៃគូមួយចំនួន ដើម្បីជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ និងបង្កើតការងារជូនប្រជាពលរដ្ឋបន្ថែម ដោយដាក់ចេញនូវវិធានការអន្តរាគមន៍ដើម្បីស្រូបយកការប៉ះទង្គិចរយៈពេលខ្លី, ដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ, ពង្រឹងភាពធន់នឹងវិបត្តិលើផ្នែកម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃស្ថាប័នសាធារណៈ។ លើសពីនេះ ចំណាយលើហេដ្ឋា-រចនាសម្ព័ន្ធរូបវន្តដែលគាំទ្រដល់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងកម្ពុជា ដែលមានគោលដៅផ្តល់ហិរញ្ញប្បទានដល់គម្រោង/កម្មវិធី ក្នុងវិស័យអាទិភាពដោយផ្តោតទៅលើ÷

- ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពាន លូ ព្រមទាំងការជួសជុលឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលរងផលប៉ះពាល់ពីជំនន់ទឹកភ្លៀង រួមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធ ដូចជា ប្រព័ន្ធចម្រោះទឹកកខ្វក់ ប្រព័ន្ធលូ អូរ ប្រឡាយរំដោះទឹកភ្លៀង និងប្រព័ន្ធបង្ហូរទឹកកខ្វក់ក្នុងខេត្តព្រះសីហនុ
- ការបន្តស្តារ និងកសាងប្រព័ន្ធធារាសាស្ត្រ និងលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ ពិសេសលើកកម្ពស់ការគ្រប់គ្រង និងទប់ទល់នឹងទឹកជំនន់

- ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់មួយចំនួនផ្សេងទៀត ពិសេសការសាងសង់អគារបន្ថែមនៅក្នុងមន្ទីរពេទ្យមួយចំនួនដែលកំពុងមានការខ្វះខាត
- ការបន្តអនុវត្តន៍សាកល្បងនូវកម្មវិធីសាច់ប្រាក់ពលកម្ម (Cash For Work) ដែលជាអន្តរាគមន៍ដោយត្រង់របស់រាជរដ្ឋាភិបាលក្នុងការបង្កើតការងារនៅទីជនបទ
- ការបន្តវិនិយោគលើវិស័យអគ្គិសនី ដើម្បីបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់អគ្គិសនី និងបញ្ចុះថ្លៃអគ្គិសនីនៅជនបទ
- ការបន្តផ្តល់ថវិកាគម្រោងវិនិយោគផ្ទាល់ក្នុងខេត្តត្បូងឃ្មុំ
- ការបន្តវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យកសិកម្ម និងការវិនិយោគលើការជំរុញផលិតកម្មស្បៀង ជាពិសេសការផលិតស្រូវ និងបន្លែ។

## ៣.៣. ថវិកាកម្មវិធីនៃក្រសួង ស្ថាប័ន

ក្រសួង ស្ថាប័នទាំង ៣៩ បានអនុវត្តថវិកាកម្មវិធីពេញលេញចាប់ពីឆ្នាំ ២០១៨។

**២០១៥**

១. ក្រ. អប់រំ,
២. ក្រ. សុខាភិបាល,
៣. ក្រ. ការងារ,
៤. ក្រ. កិច្ចការនារី,
៥. ក្រ. កសិកម្ម,
៦. ក្រ. អភិវឌ្ឍជនបទ,
៧. ក្រ. សាធារណៈការ,
៨. ក្រ. សេដ្ឋកិច្ច និងហិរញ្ញវត្ថុ,
៩. ក្រ. ដែនដី,
១០. ក្រ. យុត្តិធម៌

**២០១៦**

១. ក្រ. ព័ត៌មាន,
២. ក្រ. បរិស្ថាន,
៣. ក្រ. សង្គមកិច្ច,
៤. អាកាសចរស៊ីវិល,
៥. ក្រ. ពាណិជ្ជកម្ម,
៦. ក្រ. ប្រៃសណីយ៍,
៧. ក្រ. ទេសចរណ៍,
៨. ក្រ. ធនធានទឹក,
៩. តុលាកាកំពូល,
១០. សាលាឧទ្ធរណ៍
១១. អគ្គ. រដ្ឋសភា,
១២. អគ្គ. ព្រឹទ្ធសភា,
១៣. ក្រ. ការបរទេស,
១៤. អាជ្ញាធរសវនកម្មជាតិ,
១៥. អង្គភាពប្រឆាំងអំពើពុករលួយ,

**២០១៧**

១. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
២. ក្រុមប្រឹក្សាធម្មនុញ្ញ,
៣. ក្រ. ព្រះបរមរាជវាំង,
៤. ក្រ. ទំនាក់ទំនងសភា,
៥. គណៈកម្មការជាតិរៀបចំការបោះឆ្នោត
៦. ក្រ. ធម្មការ,
៧. ក្រ. រ៉ែ និងថាមពល
៨. ក្រ. វប្បធម៌
៩. ក្រ. មុខងារ,
១០. ក្រ. ផែនការ,
១១. ក្រ. ឧស្សាហកម្ម,

**២០១៨**

១. ក្រ. មហាផ្ទៃ,
២. ក្រ. ការពារជាតិ,
៣. ទីស្តីការគណៈរដ្ឋមន្ត្រី,

**ក្រសួងអប់រំ យុវជន និងកីឡា** មានគោលនយោបាយចំនួន២ គឺ÷

ទី ១ ÷ ធានាឲ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

ទី ២ ÷ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

៣ ២០៧ ២២០

លានរៀល

១. ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ

២. ការអភិវឌ្ឍឧត្តមសិក្សានិងការស្រាវជ្រាវ

៣. ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា

៤. ការអភិវឌ្ឍជំនាញបច្ចេកទេស និងជំនាញទន់សម្រាប់យុវជន

៥. ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១ នៃឧបសម្ព័ន្ធ</u>

**ក្រសួងសុខាភិបាល** មានគោលនយោបាយចំនួន ១ គឺ÷លើកកម្ពស់លទ្ធផលសុខភាពប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង និង បង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុក្នុងការប្រើប្រាស់សេវាថែទាំសុខភាព។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៤ គឺ÷

១ ៦៣៦ ៤៥៧

លានរៀល

១. សុខភាពបន្តពូជយុវវ័យ មាតា ទារក កុមារ និងអាហារូបត្ថម្ភ

២. ប្រយុទ្ធជំងឺឆ្លង

៣. ប្រយុទ្ធជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត

៤. ពង្រឹងប្រព័ន្ធសុខាភិបាល

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ២នៃឧបសម្ព័ន្ធ</u>

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា**មានគោលនយោបាយចំនួន ១ គឺ÷ ពង្រឹងប្រព័ន្ធគាំពារ និងផ្តល់សេវាសុខុមាលភាពសង្គម ប្រកបដោយប្រសិទ្ធភាព និងសមធម៌។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៣ គឺ÷

**១ ១៣៧ ០៦១ លានរៀល**

១. សេវាសុខុមាលភាពសង្គម

២. ការគ្រប់គ្រងរបបសន្តិសុខសង្គម និងសេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ

៣. ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣នៃឧបសម្ព័ន្ធ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**: មានគោលនយោបាយចំនួន ១ គឺ÷ ការអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

**២៦៧ ៣៩៥ លានរៀល**

១. ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ

២. ទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

៣. បរិយាកាសមុខរបរ និងការងារកាន់តែទូលំទូលាយ

៤. ការអភិវឌ្ឍរបបសន្តិសុខសង្គម

៥. ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៤នៃឧបសម្ព័ន្ធ

**ក្រសួងបរិស្ថាន** មានគោលនយោបាយចំនួន ១ គឺ÷ កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និង ការគ្រប់គ្រងធនធានធម្មជាតិឱ្យមាននិរន្តរភាព។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

៥៥ ៧១៦ លានរៀល

១. កិច្ចគាំពារបរិស្ថាន

២. ការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន

៣. ការគ្រប់គ្រងការអភិវឌ្ឍដោយចីរភាព

៤. ការគ្រប់គ្រងចំណេះដឹង និងព័ត៌មានបរិស្ថាន

៥. សេវាគាំទ្រការងារបរិស្ថាន និងធនធានធម្មជាតិ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៥នៃឧបសម្ព័ន្ធ</u>

**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** មានគោលនយោបាយចំនួន ១ គឺ÷ អភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

១៨៥ ១៥១ លានរៀល

១. កិច្ចគាំពារបេតិកភណ្ឌវប្បធម៌រូបី

២. ការលើកស្ទួយបេតិកភណ្ឌវប្បធម៌អរូបី

៣. ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៦នៃឧបសម្ព័ន្ធ</u>

**ក្រសួងព័ត៌មាន**មានគោលនយោបាយចំនួន ១ គឺ÷ ការលើកកម្ពស់សេវាព័ត៌មាន ធានាឱ្យបាននូវសិទ្ធិទទួលបានព័ត៌មានពេញលេញ ទាន់ពេលវេលា និងសុក្រឹត្យ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

<u>៥០ ១៧០</u>
<u>លានរៀល</u>

ការគ្រប់គ្រង និងអភិវឌ្ឍវិស័យព័ត៌មាន

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៧នៃឧបសម្ព័ន្ធ</u>

**ក្រសួងកិច្ចការនារី**មានគោលនយោបាយចំនួន ១ គឺ÷ ប្រែក្លាយស្ត្រីជាកម្លាំងចលករ ដ៏សំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ កែប្រែស្ថានភាពសេដ្ឋកិច្ច សង្គម និងនយោបាយរបស់ស្ត្រី ឱ្យមានការប្រែប្រួលល្អប្រសើរជាលំដាប់ ដើម្បីសុភមង្គលគ្រួសារ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៤ គឺ÷

<u>៥៥ ២៦២</u>
<u>លានរៀល</u>

១. កែប្រែស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ស្ត្រី
២. កិច្ចការពារផ្លូវច្បាប់ចំពោះស្ត្រី និងកុមារ
៣. ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយជាតិ និងតាមវិស័យ
៤. ការគ្រប់គ្រង និងការអភិវឌ្ឍស្ថាប័ន

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៨នៃឧបសម្ព័ន្ធ</u>

**ក្រសួងធម្មការ និងសាសនា** មានគោលនយោបាយចំនួន ១ គឺ÷ លើកកម្ពស់សាសនារបស់រដ្ឋ តម្លៃសីលធម៌សង្គម និងសុខដុមនីយកម្មសាសនា។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

៧៣ ៨២៧ លានរៀល

សុខដុមនីយកម្មសាសនានៅកម្ពុជា

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៩នៃឧបសម្ព័ន្ធ

**ក្រសួងទេសចរណ៍**មានគោលនយោបាយចំនួន ១ គឺ÷ ជំរុញកំណើនទេសចរណ៍ និងបង្កើនតម្លៃបន្ថែមតាមរយៈវិស័យទេសចរណ៍នៅកម្ពុជា។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

១០២ ៥៦៦ លានរៀល

១. ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
២. ការអភិវឌ្ឍទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ
៣. សេវាគាំទ្រដំណើរការទូទៅរបស់ស្ថាប័ន

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ១០នៃឧបសម្ព័ន្ធ

**ក្រសួងធនធានទឹក និងឧតុនិយម**មានគោលនយោបាយចំនួន ១ គឺ÷ ការគ្រប់គ្រង អភិវឌ្ឍន៍ និងអភិរក្សធនធានទឹកប្រកបដោយប្រសិទ្ធភាពខ្ពស់ សមធម៌ និងនិរន្តរភាព។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

១៦៤ ០៤២
លានរៀល

១. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក

២. ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត

៣. ការការពារ និងអភិរក្សធនធានទឹក

៤. ការគ្រប់គ្រងព័ត៌មានស្ដីពីធនធានទឹក និងឧតុនិយម

៥. ការគ្រប់គ្រងរដ្ឋបាល និងសេវាទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១១នៃឧបសម្ព័ន្ធ</u>

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**មានគោលនយោបាយចំនួន ១ គឺ÷ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

២៨៣ ០៧៦
លានរៀល

១. ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច

២. ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ

៣. ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

៤. ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ

៥. ការបង្កើនប្រសិទ្ធភាព សេវាគាំទ្រ និងការអភិវឌ្ឍធនធានមនុស្ស

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១២នៃឧបសម្ព័ន្ធ</u>

**ក្រសួងពាណិជ្ជកម្ម** មានគោលនយោបាយចំនួន ១ គឺ÷ ពង្រឹង និង ជំរុញការអភិវឌ្ឍវិស័យពាណិជ្ជកម្ម។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៣ គឺ÷

១២៦ ៩៣៦ លានរៀល

១. ការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍន៍វិស័យឯកជន

២. ការត្រួតពិនិត្យគុណភាព សុវត្ថិភាពផលិតផលទំនិញនិងសេវា

៣. កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស និងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ១៣ នៃឧបសម្ព័ន្ធ

**ក្រសួងរ៉ែ និងថាមពល** មានគោលនយោបាយចំនួន ១ គឺ÷ ពង្រឹងនិងបង្កើនចំណូលឧស្សាហកម្មនិស្សារណកម្ម ពង្រឹងសមត្ថភាពនិងសន្តិសុខថាមពល រួមទាំង សន្តិសុខសុវត្ថិភាពវិទ្យុសកម្ម ដោយឈរលើមូលដ្ឋានសេដ្ឋកិច្ច សង្គម និងបរិស្ថាន។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៤ គឺ÷

៧៤ ២៤៣ លានរៀល

១. ការអភិវឌ្ឍធនធានរ៉ែ

២. ការអភិវឌ្ឍវិស័យប្រេងកាត

៣. ការអភិវឌ្ឍ និងការគ្រប់គ្រងវិស័យថាមពល

៤. ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ១៤នៃឧបសម្ព័ន្ធ

**ក្រសួងសាធារណការនិងដឹកជញ្ជូន**មានគោលនយោបាយចំនួន ១ គឺ÷ អភិវឌ្ឍន៍ ថែទាំ និងគ្រប់គ្រងសំណង់សាធារណការ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន មធ្យោបាយសេវាកម្មដឹកជញ្ជូនគ្រប់ប្រភេទ និងភស្តុភារកម្មប្រកបដោយសុវត្ថិភាព និង ប្រសិទ្ធភាព។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន២ គឺ÷

៩០៦ ៩០២ លានរៀល

១. អភិវឌ្ឍន៍ ជួសជុល ថែទាំ និងគ្រប់គ្រងសំណង់សាធារណការ ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងភស្តុភារកម្ម
២. គាំទ្រគោលនយោបាយសាធារណការ, ដឹកជញ្ជូន, ការអភិវឌ្ឍន៍ធនធានមនុស្ស និងគ្រប់គ្រងរដ្ឋបាលទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១៥នៃឧបសម្ព័ន្ធ</u>

**ក្រសួងអភិវឌ្ឍន៍ជនបទ** មានគោលនយោបាយចំនួន ១ គឺ÷ លើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្នទាំងផ្នែក សេដ្ឋកិច្ចសង្គមនិងវប្បធម៌។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៤ គឺ÷

១៥៦ ៧២៣ លានរៀល

១. អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍
២. កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ
៣. ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ
៤. ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១៦នៃឧបសម្ព័ន្ធ</u>

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** មានគោលនយោបាយចំនួន ១ គឺ÷ បន្តអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

៧៩ ៥៩៥ លានរៀល

១. ការការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យប្រៃសណីយ៍, ទូរគមនាគន៍ និងការគ្រប់គ្រងធនធានវិសាលគមន៍ប្រេកង់វិទ្យុ

២. ការគ្រប់គ្រង និងអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

៣. ការគាំទ្រផ្នែកស្ថាប័ន

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១៧នៃឧបសម្ព័ន្ធ</u>

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម** មានគោលនយោបាយចំនួន ១ គឺ÷ ការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច មធ្យម និងសិប្បកម្មនិងការផ្គត់ផ្គង់ទឹកស្អាត ដើម្បីឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី ៤។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៣ គឺ÷

៦២ ៦៤៤ លានរៀល

១. ការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម និងការផ្គត់ផ្គង់ទឹកស្អាត

២. ការគ្រប់គ្រងស្តង់ដារ និងមាត្រាសាស្ត្រ

៣. សេវាទ្រទ្រង់ដំណើរការកិច្ចការទូទៅ ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម និងសិប្បកម្ម

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១៨នៃឧបសម្ព័ន្ធ</u>

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** មានគោលនយោបាយចំនួន ១ គឺ÷ លើកកម្ពស់គុណភាពសេវាកម្ម និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិលដើម្បីធានាសុវត្ថិភាព និងសន្តិសុខសម្រាប់សហប្រតិបត្តិការដឹកជញ្ជូនផ្លូវអាកាស។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន២ គឺ÷

៦០ ១៦៤
លានរៀល

១. សុវត្ថិភាព សន្តិសុខ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល
២. ការអភិវឌ្ឍស្ថាប័ន និងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១៩នៃឧបសម្ព័ន្ធ</u>

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** មានគោលនយោបាយចំនួន ២ គឺ÷

ទី ១ ÷ ពង្រឹង និងបង្កើនប្រសិទ្ធភាពគ្រប់គ្រងសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។

ទី ២ ÷ ពង្រឹង និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ និង ទ្រព្យសម្បត្តិរដ្ឋ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

១. ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសេដ្ឋកិច្ច
២. ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង ការត្រួតពិនិត្យ និងការអភិវឌ្ឍ វិស័យហិរញ្ញវត្ថុ
៣. ពង្រឹង និងបង្កើនស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រង ការកៀរគរចំណូលថវិកាជាតិ និងទ្រព្យសម្បត្តិរដ្ឋ
៤. ពង្រឹង និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយសាធារណៈ
៥. ពង្រឹង និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការគាំទ្រទូទៅនិងការធានាគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៨៦៦ ០១៩
លានរៀល

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ២០ នៃឧបសម្ព័ន្ធ</u>

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** មានគោលនយោបាយចំនួន ១ គឺ÷
ពង្រឹងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សតាមរយៈការបោះឆ្នោត។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន២ គឺ÷

៦៤ ៦២២
លានរៀល

១. រៀបចំបទបញ្ញា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត
២. កិច្ចដំណើរការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២១នៃឧបសម្ព័ន្ធ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** មានគោលនយោបាយចំនួន ១ គឺ÷
កំណែទម្រង់វិស័យដីធ្លី និងការអភិវឌ្ឍន៍វិស័យសំណង់ និងលំនៅឋាន។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

១៣៧ ២៥៩
លានរៀល

១. ពង្រឹងការគ្រប់គ្រងដីធ្លី
២. ពង្រឹងការរៀបចំដែនដី និងនគរូបនីយកម្ម
៣. ពង្រឹងការគ្រប់គ្រងវិស័យសំណង់
៤. ការគាំទ្រដំណើរការរដ្ឋបាល និងអភិវឌ្ឍន៍ស្ថាប័ន
៥. លំនៅឋាន

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២២នៃឧបសម្ព័ន្ធ

**ក្រសួងមុខងារសាធារណៈ** មានគោលនយោបាយចំនួន ១ គឺ÷ គ្រប់គ្រង និងអភិវឌ្ឍវិស័យមុខងារសាធារណៈ និងពង្រឹងការកែលម្អអភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៤ គឺ÷

**៦១ ២៣៨ លានរៀល**

១. កំណែទម្រង់រដ្ឋបាលសាធារណៈ
២. ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យសាធារណៈ
៣. ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងការកែលម្អរបៀបរបបគ្រប់គ្រង និងចាត់ចែងការងារ
៤. ការគាំទ្រ និង ការសម្របសម្រួលទូទៅរបស់ក្រសួង និងមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២៣នៃឧបសម្ព័ន្ធ

**ក្រសួងផែនការ** មានគោលនយោបាយចំនួន ១ គឺ÷ អភិវឌ្ឍ និងជំរុញការអនុវត្តគោលនយោបាយ និងយុទ្ធសាស្រ្តវិស័យ ផែនការស្ថិតិ វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

**៥៧ ២៧១ លានរៀល**

១. អភិវឌ្ឍយុទ្ធសាស្រ្តសម្រាប់ការអភិវឌ្ឍក្នុងវិស័យផែនការ
២. ពង្រឹងប្រព័ន្ធស្ថិតិជាតិ
៣. សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយជាតិប្រជាជន២០១៦-២០៣០
៤. សម្របសម្រួល និងជំរុញការអភិវឌ្ឍវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា
៥. ការគាំទ្រកិច្ចការរដ្ឋបាលទូទៅ និងការអភិវឌ្ឍស្ថាប័ន

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២៤នៃឧបសម្ព័ន្ធ

**ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** មានគោលនយោបាយចំនួន ១ គឺ÷ ពង្រឹង និងលើកកម្ពស់គោលនយោបាយការបរទេស ក្នុងការបន្តធ្វើសមាហរណកម្មកម្ពុជាកាន់តែស៊ីជម្រៅទៅក្នុងតំបន់ និងពិភពលោក។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

១៥៨ ៥២១ លានរៀល

ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងពង្រីកទំនាក់ទំនងការងារការទូត នៅលើពិភពលោក

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២៥នៃឧបសម្ព័ន្ធ

**អង្គភាពប្រឆាំងអំពើពុករលួយ** មានគោលនយោបាយចំនួន ១ គឺ÷ ពង្រឹងអភិបាលកិច្ចល្អតាមរយៈការកាត់បន្ថយអំពើពុករលួយគ្រប់រូបភាព គ្រប់វិស័យ និងគ្រប់ជាន់ថ្នាក់។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន២ គឺ÷

៥៣ ៦០៨ លានរៀល

១. វិធានការអប់រំបង្ការទប់ស្កាត់ និងអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ

២. សេវាកម្មគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២៦នៃឧបសម្ព័ន្ធ

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**មានគោលនយោបាយចំនួន ១ គឺ÷ លើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន និងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

១៦ ២០០ លានរៀល

ពង្រឹង និងពង្រីកវិស័យឯកជន និងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ២៧នៃឧបសម្ព័ន្ធ</u>

**អាជ្ញាធរសវនកម្មជាតិ**មានគោលនយោបាយចំនួន ១ គឺ÷ រួមចំណែកលើកស្ទួយអភិបាលកិច្ចល្អ និងការប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

១៤ ៩៣៦ លានរៀល

ការគ្រប់គ្រង និងសម្របសម្រួលការងារសវនកម្ម

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ២៨នៃឧបសម្ព័ន្ធ</u>

**ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច** មានគោលនយោបាយចំនួន ១ គឺ÷ ការលើកកម្ពស់អភិបាលកិច្ចល្អតាមរយៈ ការអប់រំ បង្ការ ទប់ស្កាត់បាតុភាពអសកម្ម បង្កើនគណនេយ្យភាព ប្រសិទ្ធភាពការងារ និង ពង្រឹងនីតិរដ្ឋ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

៤៤ ២២៩ លានរៀល

កិច្ចការទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ២៩នៃឧបសម្ព័ន្ធ</u>

**ក្រុមប្រឹក្សាធម្មនុញ្ញ**មានគោលនយោបាយចំនួន ១ គឺ÷ គោរពនីតិរដ្ឋ ការពារឯករាជ្យភាព អនុវត្តអព្យាក្រឹតភាពក្នុងការបំពេញមុខងារ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

**១៣ ៧០០ លានរៀល** ធានាការគោរពនីតិរដ្ឋ ការពារឯករាជ្យភាព អនុវត្តអព្យាក្រឹតភាព

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣០នៃឧបសម្ព័ន្ធ

**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**មានគោលនយោបាយចំនួន ១ គឺ÷ ពង្រឹង និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

**៥៧ ៣០៤ លានរៀល** ការអនុវត្តមុខងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋាន

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣១នៃឧបសម្ព័ន្ធ

**អគ្គលេខាធិការដ្ឋានរដ្ឋសភា**មានគោលនយោបាយចំនួន ១ គឺ÷ លើកកម្ពស់នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ តាមរយៈការអនុវត្តតួនាទីនៃមុខងារនីតិបញ្ញត្តិ និងជំរុញសមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

**១៤៣ ៤៣៧ លានរៀល**

១. ការអនុវត្តមុខងារ និងតួនាទីនីតិបញ្ញត្តិរបស់ស្ថាប័នរដ្ឋសភា

២. កិច្ចការទូតរបស់រដ្ឋសភាក្នុងតំបន់ និងក្នុងពិភពលោក

៣. កិច្ចការធនធានមនុស្ស និងបង្កើនគុណភាពសេវាជូនរដ្ឋសភា

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣២នៃឧបសម្

**ក្រសួងព្រះបរមរាជវាំង**មានគោលនយោបាយចំនួន ១ គឺ÷ បម្រើសេវាឱ្យកាន់តែល្អប្រសើរ ថ្វាយព្រះមហាក្សត្រ និងសម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងការបំពេញព្រះរាជបេសកកម្មបម្រើប្រទេសជាតិ ឱ្យមានការអភិវឌ្ឍន៍ និងមានកិត្តិយសលើឆាកអន្តរជាតិ តាមព្រះរាជកិច្ចរបស់ព្រះអង្គដែលរដ្ឋធម្មនុញ្ញបានកំណត់។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

<u>១០២ ៨១៥ លានរៀល</u> ព្រះរាជកិច្ច ព្រះមហាក្សត្រ និង សម្តេចព្រះវររាជមាតាជាតិខ្មែរ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៣៣នៃឧបសម្ព័ន្ធ</u>

**ទីស្តីការគណៈរដ្ឋមន្ត្រី**មានគោលនយោបាយចំនួន ១ គឺ÷ បន្តដឹកនាំសម្របសម្រួលការរៀបចំ និងអនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ ដើម្បីការអភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្រ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១គឺ÷

<u>៤២៧ ០២០ លានរៀល</u> ពង្រឹងប្រសិទ្ធិភាពការកសាង និងអនុវត្តគោលនយោបាយនិងកំណែទម្រង់រដ្ឋ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៣៤នៃឧបសម្ព័ន្ធ</u>

**ក្រសួងការពារជាតិ**មានគោលនយោបាយចំនួន ១ គឺ÷ ការពារអធិបតេយ្យ បូរណភាពទឹកដី រក្សាសន្តិសុខ និងសុវត្ថិភាពសង្គម។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៤ គឺ÷

<u>២ ៥៣៦ ៧២៨ លានរៀល</u>

១. ដឹកនាំបញ្ជា ហ្វឹកហ្វឺន ធ្វើប្រតិបត្តិការ ការពារសុខសន្តិភាព និងរក្សាសណ្តាប់ធ្នាប់សង្គម
២. សហប្រតិបត្តិការយោធាក្នុងតំបន់ និងអន្តរជាតិ
៣. ថែទាំគ្រឿងបំពាក់បច្ចេកទេស វិស្វកម្ម និងបញ្ជូនសារ
៤. សេវាគាំទ្ររដ្ឋបាលទូទៅ និងហិរញ្ញវត្ថុ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៣៥នៃឧបសម្ព័ន្ធ</u>

**ក្រសួងមហាផ្ទៃ (ផ្នែកសន្តិសុខសាធារណៈ)** មានគោលនយោបាយចំនួន ១ គឺ÷ ពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៤ គឺ÷

១ ៧០៣ ៣៤០ លានរៀល

១. ការការពារសន្តិសុខជាតិ និងការរក្សាសណ្ដាប់ធ្នាប់សាធារណៈ
២. កិច្ចការអត្តសញ្ញាណបុគ្គល និងអន្តោប្រវេសន៍
៣. កិច្ចការសន្តិសុខមិនប្រពៃណី
៤. សេវាគាំទ្រកិច្ចប្រតិបត្តិការទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣៦នៃឧបសម្ព័ន្ធ

**ក្រសួងមហាផ្ទៃ (ផ្នែករដ្ឋបាលទូទៅ)** មានគោលនយោបាយចំនួន ១ គឺ÷ ដឹកនាំ គ្រប់គ្រងរដ្ឋបាលដែនដី ដើម្បីលើកកម្ពស់ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

២៥៥ ២៦១ លានរៀល

១. ការគ្រប់គ្រងរដ្ឋបាលដែនដី
២. ការគ្រប់គ្រងពន្ធនាគារ
៣. សេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣៧នៃឧបសម្ព័ន្ធ

**ក្រសួងយុត្តិធម៌** មានគោលនយោបាយចំនួន ១ គឺ÷ បង្កើនប្រសិទ្ធភាពនៃការផ្ដល់សេវាយុត្តិធម៌។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

១៦៥ ០៤៩ លានរៀល

១. កិច្ចការច្បាប់
២. កិច្ចការតុលាការ
៣. សេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២០ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣៨នៃឧបសម្ព័ន្ធ

### ៣.៤. ការកំណត់ពិតាននៃការខ្ចីសម្រាប់ឆ្នាំ ២០២០

